# អ្នកស្រលាញ់ភេទដូចគ្នាបន្តស្នើសុំច្បាប់ស្តីពីអាពាហ៍ពិពាហ៍ ខណៈរដ្ឋាភិបាលថាត្រូវការពេលផ្លាស់ប្តូរផ្នត់គំនិតសង្គម

២ មករា ២០២៤ ម៉ោង ១១:៥៩

ស៊ើង និមល់



*គូស្នេហ៍ស្រឡាញ់ភេទដូចគ្នា ស៊ុយ ស៊ីថា និង ហុង សារឿន បានរៀបការនិងរស់នៅជាមួយគ្នាយ៉ាងសុខសប្បាយតាំងពីឆ្នាំ១៩៧៥។ រូបភាពថតកាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣។ (ខេមបូចា/ ស៊ើង និមល់)*

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍សម្រាប់ភេទដូចគ្នាទំនងជាមានការពិបាកក្នុងការបង្កើត និងអនុវត្ត ខណៈមន្ត្រីរដ្ឋាភិបាលបារម្ភថាវាអាចធ្វើឲ្យប៉ះពាល់ដល់ទំនៀមទម្លាប់ និងប្រពៃណី។

ក្នុងបរិបទប្រទេសកម្ពុជា ការរើសអើងលើសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាគឺមិនទាន់មានភាពល្អប្រសើរនៅឡើយទេ នេះបើតាមការសង្កេតរបស់លោក ស្រ៊ាង ចិន្តា តំណាងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជារបស់រដ្ឋាភិបាល។ ការណ៍នេះ លោកថាវាបង្ហាញថាសង្គមមិនទាន់ទទួលយកជាទូទៅចំពោះច្បាប់ស្តីពីអាពាហ៍ពិពាហ៍សម្រាប់អ្នកស្រលាញ់ភេទដូចគ្នានៅឡើយ។

រឿងដែលត្រូវធ្វើដំបូងគេមុននឹងចេញសេចក្ដីព្រាងច្បាប់ គឺត្រូវអប់រំប្រជាពលរដ្ឋឲ្យយល់ថាអ្វីជាសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាជាមុនសិន ដើម្បីបញ្ឈប់ការរើសអើង ទោះបីជាត្រូវការពេលច្រើនក៏ដោយ។

លោកបន្តថា៖ *«យើងត្រូវដឹងថាច្បាប់បង្កើតឡើងដើម្បីរក្សាភាពសុខដុមរមនាក្នុងសង្គម។ បើសិនជាច្បាប់ [អាពាហ៍ពិពាហ៍សម្រាប់អ្នកស្រលាញ់ភេទដូចគ្នា]នាំឲ្យមានការបែកបាក់សង្គមរបស់យើង យើងមិនអាចបង្កើតវាបានទេ»*។ លោកបន្ថែមថា៖ *«យើងត្រូវការពេលវេលាដើម្បីផ្លាស់ប្ដូរផ្នត់គំនិតរបស់សង្គម។ ការណ៍នេះត្រូវការការអប់រំ និងការផ្សព្វផ្សាយ [ព័ត៌មាន] ដែលត្រូវការពេលវេលា»*។

លោក ចិន្ដា មានប្រសាសន៍ថាលោកតែងតែសង្កេតឃើញប្រជាពលរដ្ឋបញ្ចេញមតិលើបណ្ដាញសង្គមនៅពេលមានការបង្ហោះរូបភាពក្នុងកម្មវិធីអាពាហ៍ពិពាហ៍របស់អ្នកស្រលាញ់ភេទដូចគ្នាលើអនឡាញ។ លោកថាវាមានពីរផ្នែក មួយគាំទ្រ និងមួយទៀតជំទាស់។ លោកថា៖ *«ដូចនេះ ការព្រាងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍សម្រាប់អ្នកស្រលាញ់ភេទដូចគ្នាត្រូវការការទទួលស្គាល់ពីសង្គមជាមុនសិន»*។

ជាមន្ត្រីចូលនិវត្តន៍ ស៊យ ស៊ីថា វ័យ៧២ឆ្នាំ ដែលបានរៀបការជាមួយអ្នកស្រី ហុង សារឿន តាំងពីឆ្នាំ១៩៧៥ យល់ឃើញថាច្បាប់ស្ដីពីអាពាហ៍ពិពាហ៍សម្រាប់អ្នកស្រលាញ់ភេទដូចគ្នាមិនបានបំផ្លាញទំនៀមទម្លាប់ប្រពៃណីរបស់កម្ពុជាទេ។

អតីតមន្ត្រីក្រសួងព័ត៌មានរូបនេះលើកឡើងថា៖ *«ខ្ញុំមិនយល់ថាអ្នកស្រឡាញ់ភេទដូចគ្នាធ្វើឲ្យខូចខាតប្រពៃណីទេ។ ប្រហែលព្រោះតែច្បាប់បច្ចុប្បន្នចែងថាបុរសអាចរៀបការជាមួយស្ត្រី...ខ្ញុំមិនគិតថាវាជារឿងខុសនោះទេ ប៉ុន្តែបើពួកគេយល់ពីអារម្មណ៍របស់យើង ពួកគេគួរតែជួយយើង»*។

អ្វីទាំងនេះហើយ ដែល ស៊ីថា និយាយថាអ្នកស្រឡាញ់ភេទដូចគ្នារងសម្ពាធជាច្រើនតាំងពីគ្រួសារ សង្គម និងអ្នកប្រពៃណីនិយម។

នៅកម្ពុជា ការយល់ឃើញអំពីភាពស្របច្បាប់នៃការរៀបអាពាហ៍ពិពាហ៍សម្រាប់អ្នកស្រលាញ់ភេទដូចគ្នាហាក់មានភាពវិជ្ជមានគឺ៥៧ភាគរយ ដែលធ្វើឲ្យកម្ពុជាស្ថិតក្នុងប្រទេសកំពូលតារាងបន្ទាប់ពីជប៉ុន វៀតណាម ថៃ និងហុងកុង។ នេះបើតាមការស្ទង់មតិមួយរបស់មជ្ឈមណ្ឌលស្រាវជ្រាវ Pew មានមូលដ្ឋានក្នុងទីក្រុងវ៉ាស៊ីនតោន។ ការស្ទង់មតិនេះធ្វើឡើងលើមនុស្សចំនួន១ ៥០២នាក់មកពីភូមិចំនួន១៥០នៅក្នុងប្រទេសកម្ពុជា។

**គ្មានឯកសារផ្លូវការ**

ទោះបីជាអ្នកស្រឡាញ់ភេទដូចគ្នា «មានសិទ្ធិ» រៀបការជាមួយគ្នាដោយ «ត្រូវបានផ្ដល់សេរីភាពពីរដ្ឋាភិបាលកម្ពុជា» ប៉ុន្តែគូស្នេហ៍ជាច្រើនគូមិនអាចធ្វើឲ្យអាពាហ៍ពិពាហ៍របស់ពួកគេស្របច្បាប់បានទេដោយសារខ្វះឯកសារផ្លូវច្បាប់ ដូចជាសំបុត្រអាពាហ៍ពិពាហ៍ ឬសៀវភៅគ្រួសារជាដើម។

លោក ចិន្តា មានប្រសាសន៍ថា៖ *«ការសម្របសម្រួលឲ្យចេញឯកសារសម្រាប់ពួកគេនៅមិនទាន់មាននៅឡើយ បើផ្អែកតាមច្បាប់របស់យើង អាពាហ៍ពិពាហ៍ស្របច្បាប់ត្រូវតែមានចុះបញ្ជី»*។

*«ឥឡូវនេះ ពួកយើងគឺដូចជាមិត្តភក្តិរស់នៅជាមួយគ្នា ពីព្រោះយើងគ្មានឯកសារទទួលស្គាល់អាពាហ៍ពិពាហ៍របស់យើង។ ហេតុនេះហើយបានជាយើងពឹងពាក់មេធាវីបញ្ជាក់ថាពួកយើងជាគ្រួសារ ដែលយល់ព្រមរស់នៅជាមួយគ្នា»* នេះបើតាមការលើកឡើងរបស់ ឃីម ដែលបដិសេធផ្ដល់ឈ្មោះពេញ។ ឃីម បន្តថា៖ *«បើសិនជាមានច្បាប់អាពាហ៍ពិពាហ៍សម្រាប់អ្នកស្រលាញ់ភេទដូចគ្នា វានឹងអាចធ្វើឲ្យយើងមានភាពងាយស្រួលក្នុងការរស់នៅ»*។

អ្នកស្រឡាញ់ភេទដូចគ្នារូបនេះមានវ័យ៣៦ឆ្នាំ ដែលបច្ចុប្បន្នធ្វើការនៅក្រុមហ៊ុនទេសចរណ៍មួយក្នុងក្រុងភ្នំពេញបានរៀបការជាមួយដៃគូរបស់ខ្លួនឈ្មោះវីណា កាលពីឆ្នាំ២០១៧។ អ្នកទាំងពីរលើកឡើងថាគូស្នេហ៍ស្រឡាញ់ភេទដូចគ្នាពិបាកក្នុងការរួមគ្នាទិញអចលនទ្រព្យ និងសុំកូនចិញ្ចឹម ដោយថាមានតែមនុស្សម្នាក់ប៉ុណ្ណោះដែលត្រូវអនុញ្ញាតឲ្យដាក់ឈ្មោះលើឯកសារទាំងនោះ ហើយមិនអាចដាក់ឈ្មោះទាំងពីរនាក់បានទេ។

ឃីម លើកឡើងថា៖ *«ប្ដីប្រពន្ធមិនអាចដាក់ឈ្មោះរួមគ្នាដើម្បីសុំកូនចិញ្ចឹម ឬដាក់ឈ្មោះកូនក្នុងសៀវភៅគ្រួសាររបស់អ្នកចិញ្ចឹមពួកគេទេ...បើសិនជារដ្ឋាភិបាលធ្វើឲ្យអាពាហ៍ពិពាហ៍សម្រាប់អ្នកស្រលាញ់ភេទដូចគ្នាស្របច្បាប់ និងផ្ដល់សំបុត្រអាពាហ៍ពិពាហ៍ វាពិតជាអស្ចារ្យណាស់សម្រាប់ពួកយើង»*។

ជាមួយគ្នានេះដែរ ស៊ីថា និយាយថាសំបុត្រអាពាហ៍ពិពាហ៍មានសារសំខាន់ណាស់សម្រាប់ប្ដីប្រពន្ធស្រឡាញ់ភេទដូចគ្នា។ គាំទ្រទៅនឹងគំនិតរបស់ ឃីម លោក ស៊ីថា យល់ឃើញដូចគ្នាថាបើសិនជាមានច្បាប់សម្រាប់អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នា វានឹងធ្វើឲ្យជីវិតអ្នកស្រឡាញ់ភេទដូចគ្នាកាន់តែងាយស្រួល ជាពិសេសការចុះឈ្មោះរួមគ្នាលើកម្មសិទ្ធិអចលនទ្រព្យ និងទទួលកូនចិញ្ចឹម។

**លុបបំបាត់ការរើសអើស**

ប្រឆាំងទៅនឹងទស្សនៈនេះ សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅតែបន្តចង់បានសិទ្ធិរបស់ពួកគេ ពិសេសសិទ្ធិទទួលបានសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់ ដូចដែលឃីម និងវីណា មានសង្ឃឹមថាថ្ងៃណាមួយកម្ពុជានឹងដាក់ចេញច្បាប់មួយនេះដូចប្រទេសផ្សេងដែរ។

វីណា និយាយថា៖ *«ខ្ញុំសង្ឃឹមថារដ្ឋាភិបាលនឹងពិចារណាច្បាប់នេះ មានការឆ្លើយតបពីរដ្ឋាភិបាល និងថានឹងមានច្បាប់មួយនេះកើតឡើង»។*

កាលពីខែកក្កដា កន្លងទៅ អតីតនាយករដ្ឋមន្ត្រីកម្ពុជា លោក ហ៊ុន សែន បានថ្លែងថាកម្ពុជាមិនអនុញ្ញាតឲ្យមានច្បាប់សមភាពអាពាហ៍ពិពាហ៍សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា ប៉ុន្តែ «ពួកគេនៅតែអាចស្រឡាញ់គ្នា និងរស់នៅជាមួយគ្នាដោយគ្មានបញ្ហា»។

លោក លឹម បូរិន អ្នកសម្របសម្រួលគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ (SOGIESC) នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាប្រាប់ខេមបូចាថា លោក និងក្រុមការងារបានចែករំលែកក្តីកង្វល់របស់ខ្លួនជាមួយរដ្ឋាភិបាលទាក់ទងនឹងការផ្ទុះការរិះគន់ពីសាធារណជន បើសិនជាច្បាប់នេះដាក់ឲ្យអនុវត្ត។

លោកមានប្រសាសន៍ថា៖ *«ពួកគាត់ត្រូវការពេលសិក្សាលើទិដ្ឋភាពច្បាប់ ដើម្បីធ្វើសេចក្តីព្រាង ឬវិសោធនកម្ម ដើម្បីធានាថាមិនមានផលអវិជ្ជមាន»។*

លោកបូរិន បន្តថាច្បាប់នេះមានផលប្រយោជន៍ច្រើនចំពោះក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ដូចជាទទួលបានការពារស្របច្បាប់លើដៃគូ ឬសមាជិកគ្រួសារ ក៏ដូចជាផលប្រយោជន៍សង្គម និងអាចលុបបំបាត់ការរើសអើសលើពួកគេផងដែរ។

## រៀបការក្រោមឈ្មោះកម្មវិធីផ្សេង

ជាមួយគ្នានេះដែរលោក ចិន្តា អះអាងថាថ្វីបើកម្ពុជាមិនមានច្បាប់ស្តីពីអាពាហ៍ពិពាហ៍សម្រាប់អ្នកស្រលាញ់ភេទដូចគ្នា គូស្នេហ៍ទាំងពីរនៅតែអាចរៀបការជាមួយគ្នា ប៉ុន្តែពួកគេអាចរៀបការក្រោមឈ្មោះថាជាពិធីខួបកំណើត ឬពិធីឡើងផ្ទះ។

ស៊ុយ ស៊ីថា ប្រាប់ខេមបូចាថា ប្តីប្រពន្ធស្រឡាញ់ភេទដូចគ្នាមិនអាចហៅពិធីអាពាហ៍ពិពាហ៍របស់ខ្លួនដោយចំហថាជាពិធីមង្គលការទេ ប៉ុន្តែពួកគេអាចចងបដានៅថ្ងៃរៀបការ និងភ្ជាប់ទៅនឹងកម្មវិធី «ខួបកំណើត» ឬ «ពិធីឡើងផ្ទះ»។

លោកបន្តថា បើទោះបីជាពួកគេអាចរៀបការ តែសង្គមនៅតែមិនទទួលស្គាល់ពួកគេថាជាគូស្វាមីស្រប ច្បាប់ ពីព្រោះពួកគេរៀបការជាមួយភេទដូចគ្នា ដែលមិនមានចែងក្នុងច្បាប់។

លោកបន្តថា៖ *«យើងមានសិទ្ធិក្នុងការរៀបការ ប៉ុន្តែពួកយើងមានតែការទទួលស្គាល់តែពីគ្រួសារ មិនមែនច្បាប់។ គ្មានច្បាប់រៀបការ ការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នានៅតែមាន»*។



*ជញ្ជាំងផ្ទះរបស់ ស៊ុយ ស៊ីថា និងហុង សារឿន បានព្យួរទៅដោយរូបថតកូនចិញ្ចឹមរបស់ពួកគាត់ និងចៅៗ។ រូបភាពថតកាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣។ (ខេមបូចា/ ស៊ើង និមល់)*

ចំពោះបទពិសោធន៍ផ្ទាល់ខ្លួន ឃីម ប្រាប់ខេមបូចា ថាដោយសារតែមិនមានច្បាប់ ខ្លួនមិនអាចសុំច្បាប់អនុញ្ញាតរៀបការបានទេ គឺមានតែរកវិធីផ្សេង។

លោកឃីមឲ្យដឹងថាលោក និងដៃគូក៏បានសម្រេចចិត្ត «រៀបការ» ក្នុងពិធីមង្គលការរបស់បងប្រុសរបស់ខ្លួន។ លោកថា៖ *«យើងឈរនៅពីក្រោយកូនកម្លោះ កូនក្រមុំ ដើម្បីស្វាគមន៍ភ្ញៀវ។ យើងអាចធ្វើបានត្រឹមតែប៉ុណ្ណឹង»*។

វីណា លើកឡើងដែរថា៖ *«យើងមិនអាចសុំច្បាប់រៀបការបានទេ។ យើងបានសុំទៅអាជ្ញាធរជាច្រើនដង ប៉ុន្តែពួកគាត់មិនព្រម»។* វីណា បន្តថាអាពាហ៍ពិពាហ៍របស់ខ្លួនមិនទទួលស្គាល់ពីសង្គមទេ ប៉ុន្តែបានការទទួលស្គាល់ពីមេធាវី ឪពុកម្ដាយ និងមិត្តភក្តិ ៕